ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា



# យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ
# ឆ្នាំ២០២៤-២០២៨

រាជធានីភ្នំពេញ ខែធ្នូ ឆ្នាំ២០២៣

# មាតិកា

*បុព្វកថា*

*ខ្លឹមសារសង្ខេបប្រតិបត្តិ*

I. សេចក្តីផ្តើម ១

II. បរិការណ៍នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ២

III. វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ៤

IV. ភាពចាំបាច់នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ ៩

V. គោលបំណង និងគោលដៅ ១០

VI. គោលការណ៍, យន្តការភាពជាដៃគូ និងឧបករណ៍គន្លឹះសម្រាប់អនុវត្តយុទ្ធសាស្ត្រ ១១

១-គោលការណ៍ ១១

២- យន្តការភាពជាដៃគូ ១២

ក-កិច្ចពិគ្រោះយោបល់ពហុភាគីថ្នាក់ជាតិ ១២

ខ- កិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍ ១២

គ-ក្រុមការងារបច្ចេកទេសចម្រុះ ១២

ឃ- វេទិកាពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ១៣

ង- កិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់រាជធានី-ខេត្ត ១៣

ច- កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការតំបន់ ១៣

ឆ- ភាពជាដៃគូសកលសម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ១៤

៣- ឧបករណ៍គន្លឹះ ១៤

ក-ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ១៤
និងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីអង្គការមិនមែនរដ្ឋាភិបាល

ខ-របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា ១៤

គ-សូចនាករតាមដានរួមគ្នា ១៥

VII. ក្របខ័ណ្ឌលទ្ធផល ១៥

VIII. សេចក្តីសន្និដ្ឋាន ១៦

# បញ្ជីគំនូរ និងតារាង

គំនូរ ៣.១ : ការកៀរគរហិរញ្ញប្បទាន ឆ្នាំ២០១៩-២០២៣ ៥

គំនូរ ៣.២ : ការបែងចែក និងការតម្រឹមហិរញ្ញប្បទានតាមវិស័យសំខាន់ៗ ឆ្នាំ២០១៩-២០២៣ ៦

គំនូរ ៣.៣ : ហិរញ្ញប្បទានតាមវិស័យសំខាន់ៗ ឆ្នាំ២០១៩-២០២៣ ៦

តារាង ៣.១ : ក្របខ័ណ្ឌលទ្ធផលស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ៨

# បុព្វកថា

ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពដ៏ត្រចះត្រចង់ជាច្រើនក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាបន្នក្នុងបរិការណ៍នៃសុខសន្តិភាពពេញលេញ, ស្ថិរភាពនយោបាយ, ការឯកភាពជាតិ, សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ និងសុខដុមរមនាសង្គម ។ ការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ជាបន្តបន្ទាប់ក្នុងរយៈពេលជាងពីរទសវត្សរ៍, ភាពជោគជ័យលើសមរភូមិប្រយុទ្ធនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ និងក្នុងការគ្រប់គ្រងផលប៉ះពាល់ពីវិបត្តិជំងឺនេះ, ទាំងផ្នែកសុខភាពសាធារណៈ ទាំងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងលំនឹងសង្គម-សេដ្ឋកិច្ច ក៏ដូចជាការទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាជនបានអនុញ្ញាតឱ្យកម្ពុជាបើកប្រទេសឡើងវិញនាចុងឆ្នាំ២០២១ ហើយបានធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចក្នុងស្រុកចាប់ផ្តើមវិលត្រឡប់ទៅរកប្រក្រតីភាពឡើងវិញ ។ សមិទ្ធផលទាំងនេះបានក្លាយជាមូលដ្ឋានគ្រឹះ ដែលអំណោយផលសម្រាប់ស្តារនិងបន្តអភិវឌ្ឍកម្ពុជាក្នុងដំណាក់កាលបន្ទាប់ខាងមុខទៀត ។

រាជរដ្ឋាភិបាលទទួលស្គាល់អំពីតួនាទីសំខាន់នៃហិរញ្ញប្បទានសហប្រតិបត្តិការ ក្នុងការបំពេញបន្ថែមឱ្យធនធានផ្ទាល់របស់កម្ពុជាសម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ។ លើមូលដ្ឋាននេះរាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើនក្នុងការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍និងភាពជាដៃគូ ទោះស្ថិតក្នុងស្ថានភាពដ៏សែនលំបាកដែលបង្កឡើងដោយការរាតត្បាតនៃជំងឺកូវីដ-១៩, ភាពតានតឹងខាងភូមិសាស្ត្រនយោបាយ និងការវិវត្តឆាប់រហ័សនៃនិម្មាបនកម្មសកល ។ ជាក់ស្តែង រាជរដ្ឋាភិបាលបន្តពង្រឹងបានភាពជាម្ចាស់និងភាពជាអ្នកដឹកនាំក្នុងការកៀរគរ, ការគ្រប់គ្រង និងតម្រង់ទិសការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ក៏ដូចជាពង្រឹងបានភាពជាដៃគូ និងលើកកម្ពស់គណនេយ្យភាពទ្វេទិស, តម្លាភាព, ស័ក្តិសិទ្ធិភាពនិងប្រសិទ្ធភាពក្នុងការប្រើប្រាស់ធនធានទាំងនេះ ដើម្បីឈានទៅសម្រេចគោលដៅក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ។

ក្នុងកិច្ចប្រជុំពេញអង្គលើកទី១ នៃគណៈរដ្ឋមន្ត្រីសម្រាប់នីតិកាលទី៧ នៃរដ្ឋសភា នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣, រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ។ ដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្របញ្ចកោណនេះ និងលើកកម្ពស់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ, យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ ត្រូវបានរៀបចំ ដោយផ្អែកលើមូលដ្ឋាននៃការវាយតម្លៃសមិទ្ធកម្មនិងបញ្ហាប្រឈមក្នុងការអនុវត្តនាពេលកន្លងមក, បរិវត្តកម្មសង្គម-សេដ្ឋកិច្ចកម្ពុជា, ការប្រែប្រួលយ៉ាងឆាប់រហ័សនៃនិម្មាបនកម្មអភិវឌ្ឍន៍សកល និងលទ្ធផលកិច្ចប្រជុំកំពូលស្តីពីភាពជាដៃគូសកលសម្រាប់ស័ក្តិសិទ្ធិភាពក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ឆ្នាំ២០២២ ។ គោលដៅចម្បងនៃយុទ្ធសាស្ត្រនេះ គឺលើកកម្ពស់ស័ក្តិសិទ្ធិភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងពង្រឹងភាពជាដៃគូប្រកបដោយបរិយាបន្ន ដើម្បីគាំទ្រដល់ការស្តារ និងពន្លឿនកំណើនសេដ្ឋកិច្ចក្រោយវិបត្តិជំងឺកូវីដ-១៩ ក៏ដូចជាគាំទ្រដល់ដំណើរការចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច និងការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយ

ចីរភាពរបស់កម្ពុជាឆ្នាំ២០៣០ ។ យុទ្ធសាស្ត្របានកំណត់គោលដៅនិងសកម្មភាពអាទិភាព, យន្តការភាពជាដៃគូ និងឧបករណ៍សម្រាប់រាជរដ្ឋាភិបាលគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ក្នុងបរិការណ៍បច្ចុប្បន្ន នៃកិច្ចអភិវឌ្ឍន៍ជាតិនិងសកល ។

យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ នេះ ត្រូវបានរៀបចំក្រោមការដឹកនាំ និងសម្របសម្រួលរបស់គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដោយមានការពិគ្រោះយោបល់ប្រកបដោយបរិយាបន្នជាមួយក្រសួងនិងស្ថាប័ន, ដៃគូអភិវឌ្ឍន៍ និងតួអង្គពាក់ព័ន្ធដទៃទៀត ។ ដោយមានការប្ដេជ្ញាខ្ពស់ក្នុងភាពជាម្ចាស់ និងការទទួលខុសត្រូវរបស់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងការគាំទ្រយ៉ាងពេញទំហឹងពីដៃគូអភិវឌ្ឍន៍ គួបផ្សំនឹងអភិក្រមក្នុងការអនុវត្តប្រកបដោយភាពបុរេសកម្ម, ខ្ញុំមានជំនឿជឿជាក់យ៉ាងមុតមាំថា ភាគីពាក់ព័ន្ធនឹងសហការយ៉ាងជិតស្និទ្ធ ដើម្បីបន្តលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ក៏ដូចជាបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាបន្ន ក្នុងគោលដៅរួមចំណែកជាមួយនឹងរាជរដ្ឋាភិបាល ដើម្បីសម្រេចគោលដៅអាទិភាពក្នុងកិច្ចអភិវឌ្ឍន៍ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ។

ថ្ងៃសុក្រ ៤រោច ខែមិគសិរ ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

# ខ្លឹមសារសង្ខេបប្រតិបត្តិ

ក្រោមការដឹកនាំដ៏ប៉ិនប្រសប់, វៃឆ្លាត និងប្រាកដនិយម ជាមួយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលដ៏ត្រចះត្រចង់ជាច្រើន ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដោយរក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ និងជាបន្តបន្ទាប់ក្នុងរយៈពេលជាងពីរទសវត្សរ៍, គ្រប់គ្រងបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងអតិផរណា, កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាជន ។

ដើម្បីបន្តដឹកនាំប្រទេសសំដៅរក្សាស្ថិរភាពនយោបាយ, សន្តិសុខសង្គម, បន្តជំរុញកំណើនសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពរបស់ប្រជាជនកម្ពុជា ពិសេសជនងាយរងគ្រោះ, **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនៅក្នុងកិច្ចប្រជុំពេញអង្គលើកទី ១ របស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣ នូវយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ដែលជារបៀបវារៈគោលនយោបាយអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី៧ នៃរដ្ឋសភា ។

រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពជាច្រើនក្នុងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ទន្ទឹមនឹងបន្តដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវបញ្ហាប្រឈមដែលកើតឡើងដោយសារបរិវត្តកម្មសង្គម-សេដ្ឋកិច្ចនៅកម្ពុជា និងការវិវត្តនៃនិម្មាបនកម្មអភិវឌ្ឍន៍តំបន់ និងសកល ។ ជោគជ័យក្នុងការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការពីមួយឆ្នាំទៅមួយឆ្នាំ ពីនីតិកាលមួយទៅនីតិកាលមួយនៃរដ្ឋាភិបាល និងភាពធន់នៃហិរញ្ញប្បទានទាំងនេះក្នុងអំឡុងពេលវិបត្តិនៃការរាតត្បាតជំងឺកូវីដ-១៩ បានបញ្ជាក់ច្បាស់ថា ហិរញ្ញប្បទានសហប្រតិបត្តិការនៅតែបន្តរក្សាតួនាទីសំខាន់ក្នុងការលើកកម្ពស់ និងជំរុញកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ។ ក្នុងន័យនេះ ការលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនៅតែបន្តជាអាទិភាពខ្ពស់របស់រាជរដ្ឋាភិបាល ។ លើមូលដ្ឋាននេះ យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ បានគូសបញ្ជាក់ពីភាពចាំបាច់នៃការរៀបចំយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ ។

ការរៀបចំយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ បានយកចិត្តទុកដាក់ដល់បរិវត្តកម្មនៃសង្គម-សេដ្ឋកិច្ចកម្ពុជា និងការវិវត្តនៃនិម្មាបនកម្មក្នុងតំបន់ និងសកលរួមមាន÷ វឌ្ឍនភាពក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ, វឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងការត្រៀមចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច, បញ្ហាប្រឈម និងកាលានុវត្តភាព ក៏ដូចជាបទពិសោធន៍ដែលទទួលបានពីសមរភូមិប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងការប្រណាំងប្រជែងខាងភូមិសាស្ត្រនយោបាយ ព្រមទាំងព្រឹត្តិការណ៍តំបន់ និងសកលដទៃទៀតដែលបានកើតឡើងក្នុងបណ្តាឆ្នាំកន្លងមក ។

យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ មានគោលបំណងបង្កើតក្របខ័ណ្ឌសម្រាប់លើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីរួមចំណែកអនុវត្តបណ្តាអាទិភាពជាតិដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ទន្ទឹមនឹងពេលដែលកម្ពុជា

ត្រៀមចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច និងឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។ ដើម្បីសម្រេចគោលបំណងខាងលើ, គោលដៅជាយុទ្ធសាស្ត្រចំនួន ៥ ត្រូវបានកំណត់ដូចតទៅ÷(១) ពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍; (២) លើកកម្ពស់ស័ក្តិសិទ្ធិភាពនៃដំណើរការយន្តការភាពជាដៃគូប្រកបដោយបរិយាបន្នរវាងរាជរដ្ឋាភិបាល និងតួអង្គអភិវឌ្ឍន៍; (៣) បង្កើនប្រសិទ្ធភាពនៃការអនុវត្តឧបករណ៍គន្លឹះ ដែលឆ្លុះបញ្ចាំងអំពីការទទួលខុសត្រូវរួមគ្នាលើលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍តាមវិស័យ និងតាមការដ្ឋានកំណែទម្រង់របស់រាជរដ្ឋាភិបាល; (៤) ជំរុញការផ្សព្វផ្សាយជាសាធារណៈឱ្យកាន់តែទូលំទូលាយថែមទៀតនូវព័ត៌មានស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍; និង(៥) អនុវត្ត និងតាមដានលទ្ធផលនៃការអនុវត្តការប្តេជ្ញាស្តីពីការលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

ទន្ទឹមនឹងគូសបញ្ជាក់គោលការណ៍សម្រាប់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍, យុទ្ធសាស្ត្រនេះបានកំណត់យន្តការភាពជាដៃគូសម្រាប់ដំណើរការ ក៏ដូចជាចង្អុលបង្ហាញនូវឧបករណ៍គន្លឹះសម្រាប់គាំទ្រការអនុវត្ត ។ យន្តការភាពជាដៃគូដែលបានកំណត់ក្នុងយុទ្ធសាស្ត្ររួមមាន ÷ កិច្ចពិគ្រោះយោបល់ពហុភាគីថ្នាក់ជាតិ, កិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍, ក្រុមការងារបច្ចេកទេសចម្រុះ, វេទិកាពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល, កិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់រាជធានី-ខេត្ត, កិច្ចសហប្រតិបត្តិការត្បូង-ត្បូងនិងកិច្ចសហប្រតិបត្តិការតំបន់ និងភាពជាដៃគូសកលសម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ ឧបករណ៍គន្លឹះរួមមាន÷ ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ, ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីអង្គការមិនមែនរដ្ឋាភិបាល, របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា និងសូចនាករតាមដានរួមគ្នា ។ យុទ្ធសាស្ត្រនេះក៏បានផ្តោតសារៈសំខាន់ទៅលើការតាមដានការអនុវត្តតាមរយៈការរៀបចំឱ្យមានក្របខ័ណ្ឌលទ្ធផល និងការកំណត់ស្ថាប័នទទួលខុសត្រូវក្នុងការដឹកនាំ និងសម្របសម្រួល ។

ផ្អែកលើតួនាទីសំខាន់នៃហិរញ្ញប្បទានសហប្រតិបត្តិការ និងតម្រូវការចាំបាច់ក្នុងការលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍, រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នឹងបន្តពង្រឹងកិច្ចសហការឱ្យកាន់តែជិតស្និទ្ធថែមទៀត ជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ សម្រាប់អនុវត្តប្រកបដោយជោគជ័យនូវយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ ដោយឈរលើគោលការណ៍ភាពជាម្ចាស់របស់រាជរដ្ឋាភិបាល, ភាពជាដៃគូស្មើភាព, តម្លាភាព និងគណនេយ្យភាពទ្វេទិស ។

## I. សេចក្តីផ្តើម

សុខសន្តិភាពពេញលេញ និងស្ថិរភាពនយោបាយ, ការឯកភាពជាតិ, សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ និងសុខដុមរមនាសង្គម ដែលជាសមិទ្ធផលធំធេង និងជាប្រវត្តិសាស្ត្រនៃ «នយោបាយឈ្នះ-ឈ្នះ» គឺជាបុរេលក្ខខណ្ឌចាំបាច់មិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។ ក្រោមការដឹកនាំប៉ិនប្រសប់, វៃឆ្លាត និងប្រាកដនិយម ជាមួយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលដ៏ត្រចះត្រចង់ជាច្រើន ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ដោយសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ និងជាបន្តបន្ទាប់ក្នុងរយៈពេលជាងពីរទសវត្សរ៍, រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, គ្រប់គ្រងបានអតិផរណា, កាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាជន ។ ប៉ុន្តែ ក្នុងបណ្តាឆ្នាំចុងក្រោយនេះ, សេដ្ឋកិច្ចកម្ពុជា ដូចគ្នានឹងសេដ្ឋកិច្ចនៃប្រទេសដទៃទៀតលើសកលលោក ត្រូវបានបន្ទុចបង្អាក់ដោយការរាតត្បាតនៃជំងឺកូវីដ-១៩, ការប្រកួតប្រជែងខាងភូមិសាស្ត្រនយោបាយ និងការរងឥទ្ធិពលពីជម្លោះ និងសង្គ្រាមតាមតំបន់មួយចំនួន ។ ទោះក្នុងស្ថានភាពបែបនេះក្តី, រាជរដ្ឋាភិបាលបានប្រកាន់នូវអភិក្រមបុរេសកម្មសម្រាប់គ្រប់គ្រងស្ថានការណ៍ និងសម្រេចបានសមិទ្ធផលធំធេងលើសមរភូមិប្រយុទ្ធនឹងជំងឺកូវីដ-១៩, គ្រប់គ្រងបានល្អនូវផលប៉ះពាល់ពីវិបត្តិនៃជំងឺនេះ ទាំងផ្នែកសុខភាពសាធារណៈ ទាំងផ្នែកសង្គម-សេដ្ឋកិច្ច និងរក្សាបានលំនឹងជីវភាពរស់នៅរបស់ប្រជាជន ។ ការអនុវត្តប្រកបដោយស័ក្តិសិទ្ធិភាពនូវក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គមឆ្នាំ២០១៦-២០២៥ បានបង្កើតលក្ខខណ្ឌអំណោយផលឱ្យកម្ពុជាបើកដំណើរការ និងពង្រីកសកម្មភាពសេដ្ឋកិច្ច និងសង្គម ដើម្បីឈានឆ្ពោះទៅរកប្រក្រតីភាពឡើងវិញ ។ ជាលទ្ធផល សេដ្ឋកិច្ចកម្ពុជាបានចាកចេញយ៉ាងឆាប់រហ័សពីអត្រាកំណើនអវិជ្ជមាននៅឆ្នាំ២០២០ មករកកំណើនវិជ្ជមានវិញនៅឆ្នាំ២០២១ ហើយរំពឹងថានឹងបន្តកំណើនវិជ្ជមាននៅបណ្តាឆ្នាំបន្តបន្ទាប់ទៀត ។

ក្នុងកិច្ចប្រជុំពេញអង្គលើកទី ១ របស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣, **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវ «យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១» ដែលជារបៀបវារៈគោលនយោបាយអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចសម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា ។ យុទ្ធសាស្ត្រនឹងត្រូវអនុវត្តឈរលើមូលដ្ឋាននៃសមិទ្ធផលនានាដែលសម្រេចបានពីការអនុវត្តយុទ្ធសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រចតុកោណទាំង ៤ ដំណាក់កាលកន្លងមក ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលទទួលស្គាល់ថា កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅតែបន្តតួនាទីសំខាន់ក្នុងការបំពេញបន្ថែមឱ្យកិច្ចប្រឹងប្រែងផ្ទាល់របស់កម្ពុជា ដើម្បីបន្តជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ពិសេសក្នុងដំណាក់កាលនៃការរាតត្បាតជំងឺកូវីដ-១៩ និងគាំទ្រដល់កិច្ចប្រឹងប្រែងស្តារប្រទេសឱ្យឈានឡើងក្នុងជំហានស្វាហាប់ និងប្រកបដោយចីរភាព ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលបន្តផ្តល់អាទិភាពលើការពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍, ការពង្រឹងភាពជាដៃគូប្រកបដោយបរិយាបន្នជាមួយតួអង្គអភិវឌ្ឍន៍ និងការលើកកម្ពស់ស័ក្តិសិទ្ធិភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីឈានទៅសម្រេចគោលដៅជាប្រទេសមានចំណូលមធ្យម

កម្រិតខ្ពស់នៅឆ្នាំ២០៣០, គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, ការចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។

ដើម្បីរួមចំណែកដល់ការអនុវត្តរបៀបវារៈគោលនយោបាយអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, រាជរដ្ឋាភិបាលបានរៀបចំយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ ។ ការរៀបចំយុទ្ធសាស្ត្រនេះបានផ្អែកលើការវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣, បរិវត្តកម្មសង្គម-សេដ្ឋកិច្ចកម្ពុជា និងការប្រែប្រួលយ៉ាងឆាប់រហ័សនៃនិម្មាបនកម្មអភិវឌ្ឍន៍សកល ក៏ដូចជាឧត្តមានុវត្តន៍ស្តីពីប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ ដែលជាឧបករណ៍គោលនយោបាយ សម្រាប់រួមចំណែកអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ បានកំណត់គោលដៅ និងសកម្មភាពអាទិភាព, យន្តការភាពជាដៃគូ, ឧបករណ៍ និងគោលការណ៍សម្រាប់អនុវត្ត ព្រមទាំងរៀបចំក្របខ័ណ្ឌសម្រាប់តាមដានលទ្ធផល ។

## II. បរិការណ៍នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ

ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, ការរៀបចំយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ ត្រូវយកចិត្តទុកដាក់ដល់បរិវត្តកម្មនៃសង្គម-សេដ្ឋកិច្ចកម្ពុជា និងការប្រែប្រួលឆាប់រហ័សនៃជវភាព និងនិម្មាបនកម្មតំបន់ និងសកលលោក ។

ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគន្លឹះជាច្រើនក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលអាចឆ្លុះបញ្ចាំងតាមរយៈការសម្រេចបានអត្រាកំណើនសេដ្ឋកិច្ចខ្ពស់ជាបន្តបន្ទាប់, ការរក្សាបាននស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ការធ្លាក់ចុះនៃអត្រាភាពក្រីក្រ, ការកែលម្អនិងការលើកកម្ពស់ជីវភាពរបស់ប្រជាជន, ការសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប និងការសម្រេចបានជាលើកដំបូងក្នុងឆ្នាំ២០២១ ក្នុងការបញ្ចូលទៅក្នុងបញ្ជីប្រទេសសម្រាប់ចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ។ ក្នុងកិច្ចការអន្តរជាតិ, រាជរដ្ឋាភិបាលសម្រេចបានជោគជ័យក្នុងការពង្រឹងទំនាក់ទំនងជាមួយបណ្តាប្រទេសក្នុងតំបន់ និងលើពិភពលោកដោយឈរលើគោលការណ៍នៃការប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យដោយផ្អែកលើច្បាប់ និងការបញ្ជូនកងកម្លាំងមួកខៀវជាបន្តបន្ទាប់ក្នុងបេសកកម្មរក្សាសន្តិភាពក្រោមឆ័ត្រអង្គការសហប្រជាជាតិ ។ ក្នុងឋានៈជាម្ចាស់ផ្ទះ និងប្រធានអាស៊ានសម្រាប់ឆ្នាំ២០២២, កម្ពុជាបានបំពេញតួនាទីប្រកបដោយជោគជ័យក្នុងការដឹកនាំអាស៊ាន, បានដោះស្រាយបញ្ហាប្រឈមស្មុគស្មាញ ទាំងក្នុងកម្រិតតំបន់ ទាំងក្នុងកម្រិតសកល ។ ទន្ទឹមនេះ កិច្ចដំណើរការដោយជោគជ័យនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និង៤១ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធនានា និងក្នុងនាមជាសហប្រធានកិច្ចប្រជុំកំពូលអាស៊ាន-សហភាពអឺរ៉ុប និងការធ្វើជាម្ចាស់ផ្ទះលើកដំបូងជាប្រវត្តិសាស្ត្រសម្រាប់ព្រឹត្តិការណ៍ប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី ១២ ក្នុងឆ្នាំ២០២៣ បានលើកកម្ពស់កិត្តិនាមរបស់កម្ពុជានៅលើឆាកអន្តរជាតិ ។ ការណ៍ទាំងនេះបានឆ្លុះបញ្ចាំងពីសមត្ថភាព និងតួនាទី

កាន់តែសកម្មរបស់កម្ពុជាក្នុងឋានៈជារដ្ឋឯករាជ្យ និងអធិបតេយ្យ, ចូលរួមដោយស្មើភាព និងពេញលេញជាមួយដៃគូនានាក្នុងការដោះស្រាយបញ្ហាអន្តរជាតិ និងពង្រឹងកិច្ចសហប្រតិបត្តិការ ។

ដូចគ្នានឹងប្រទេសដទៃទៀតលើសកលលោក, សង្គម-សេដ្ឋកិច្ចកម្ពុជាត្រូវបន្ទុចបង្អាក់ជាបណ្តោះអាសន្នដោយការរាតត្បាតនៃជំងឺកូវីដ-១៩ ។ បរិការណ៍បន្ថែមដទៃទៀតដែលពាក់ព័ន្ធនឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ និងទំនាក់ទំនងការទូតរួមមានការប្រកួតប្រជែងខាងភូមិសាស្ត្រនយោបាយ និងការរងឥទ្ធិពលពីជម្លោះ និងសង្គ្រាមតាមតំបន់មួយចំនួន ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី, ដោយប្រកាន់នូវអភិក្រមបុរេសកម្មក្នុងការគ្រប់គ្រង និងការអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដោយភាពម៉ឺងម៉ាត់ រួមជាមួយនឹងការចូលរួមរបស់ប្រជាជន, រាជរដ្ឋាភិបាលសម្រេចបានជោគជ័យលើសមរភូមិប្រយុទ្ធនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ និងគ្រប់គ្រងបានល្អប្រសើរនូវផលប៉ះពាល់ផ្នែកសុខភាពសាធារណៈ និងការរក្សាលំនឹងជីវភាពរស់នៅរបស់ប្រជាជន ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលដោះស្រាយបាននូវបញ្ហាប្រឈមជារចនាសម្ព័ន្ធ ដើម្បីលើកកម្ពស់សមត្ថភាពប្រកួតប្រជែង និងការធ្វើពិពិធកម្មសេដ្ឋកិច្ចកម្ពុជាតាមរយៈការដាក់ឱ្យអនុវត្តនូវក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារនិងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩តាមគន្លងថ្មី ឆ្នាំ២០២១-២០២៣, ក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល, ច្បាប់ស្តីពីវិនិយោគ, ច្បាប់ស្តីពីភាពជាដៃគូរវាងរដ្ឋនិងឯកជន និងការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសដៃគូ ។ ជាលទ្ធផល សេដ្ឋកិច្ចកម្ពុជាបានងើបចេញយ៉ាងឆាប់រហ័សពីអត្រាកំណើនអវិជ្ជមាននៅឆ្នាំ២០២០មកកំណើនវិជ្ជមានវិញនៅឆ្នាំ២០២១ ។ សេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ប្រមាណថាមានកំណើន ៥,២% ក្នុងឆ្នាំ២០២២ និងរំពឹងសម្រេចបានក្នុងរង្វង់អត្រា ៥,៦% ក្នុងឆ្នាំ២០២៣ ។ សមិទ្ធផលទាំងនេះបានផ្តល់មូលដ្ឋានគ្រឹះដ៏សំខាន់ សម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាក្នុងដំណាក់កាលបន្តបន្ទាប់ខាងមុខទៀត ។

ការប្រណាំងប្រជែងខាងភូមិសាស្ត្រនយោបាយ, ភាពមិនប្រាកដប្រជារបស់ពិភពលោក, ភាពតានតឹង និងអស្ថិរភាពនៅតាមតំបន់មួយចំនួន រួមផ្សំនឹងភាពផុយស្រួយនៃការទើបងើបចេញពីវិបត្តិជំងឺកូវីដ-១៩នាពេលថ្មីៗកន្លងមកនេះ បានបន្ទុចបង្អាក់ខ្សែច្រវាក់សកលនៃផលិតកម្ម និងការផ្គត់ផ្គង់ ។ ទាំងនេះជាបច្ច័យនាំឱ្យសេដ្ឋកិច្ចសកលជួបប្រទះនូវភាពមិនប្រាកដប្រជា និងថមថយកំណើន គួបផ្សំនឹងវិបត្តិអតិផរណាខ្ពស់ ដែលជំរុញឱ្យដៃគូអភិវឌ្ឍន៍មួយចំនួនអនុវត្តគោលនយោបាយគាំពារនិយមខាងសេដ្ឋកិច្ច និងពាណិជ្ជកម្ម ទន្ទឹមនឹងអនុវត្តគោលនយោបាយរឹតត្បិតធនធានសម្រាប់ផ្តល់ឱ្យប្រទេសកំពុងអភិវឌ្ឍន៍ ឬបង្វែរហិរញ្ញប្បទានទាំងនេះជាយថាហេតុទៅឱ្យតំបន់ ឬប្រទេសដែលមានតម្រូវការខ្ពស់ជាង ឬវិស័យដែលកំពុងប្រឈមនឹងបញ្ហា ឬសម្រាប់បម្រើគោលដៅមនុស្សធម៌ ។ ចំពោះសេដ្ឋកិច្ចកម្ពុជា ដែលបានធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ច និងពាណិជ្ជកម្មតំបន់ និងពិភពលោក ក៏ទទួលរងផលប៉ះពាល់ដែលអាចជះឥទ្ធិពលជាយថាហេតុ ដល់លទ្ធភាពកៀរគរធនធានក្នុងស្រុកសម្រាប់បម្រើឱ្យការវិនិយោគ និងការអនុវត្តគោលនយោបាយស្តារ និងអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមផងដែរ ។

កម្ពុជាកំពុងឈានឡើងក្នុងជំហានដឿជាក់ ឆ្ពោះទៅសម្រេចឋានៈប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០ ទន្ទឹមនឹងវឌ្ឍនភាពឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងការរៀបចំខ្លួនសម្រាប់ចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ។ ការណ៍ទាំងនេះបានលើកកម្ពស់កិត្យានុភាពកម្ពុជា

លើឆាកអន្តរជាតិ ហើយក៏ជាសក្ខីកម្មបញ្ជាក់អំពីសមិទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងការរក្សាសន្តិភាព, ស្ថិរភាពនយោបាយ, ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយចីរភាព ព្រមទាំងបង្កើតបរិយាកាសអំណោយផលសម្រាប់ទាក់ទាញវិនិយោគ ពិសេសវិនិយោគផ្ទាល់ពីបរទេស ។ ប៉ុន្តែ ការចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច អាចនាំដល់ការបាត់បង់ភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម,លទ្ធភាពថមថយនៃហិរញ្ញប្បទានឥតសំណង ដែលអាចជំនួសដោយឥណទានសម្បទាន, ការប្រែប្រួលលក្ខខណ្ឌសម្បទាននៃឥណទាន និងការបាត់បង់ទាំងស្រុង ឬមួយផ្នែកនៃលទ្ធភាពទទួលបានវិធានការគាំទ្រមួយចំនួនពាក់ព័ន្ធនឹងពាណិជ្ជកម្ម ។ លើមូលដ្ឋាននេះ ការត្រៀមរៀបចំ និងអនុវត្តយុទ្ធសាស្ត្រអន្តរកាលសម្រាប់ចាកចេញពីប្រទេសមានការអភិវឌ្ឍតិចតួច គឺជាកិច្ចការអាទិភាពមួយរបស់រាជរដ្ឋាភិបាល ដើម្បីកម្ពុជាអាចចាកចេញបានជាស្ថាពរពីក្រុមប្រទេសនេះ និងបន្តអភិវឌ្ឍឈានឡើងក្នុងភាពស្វាហាប់ និងជឿជាក់ ។ ក្នុងដំណាក់កាលអន្តរកាលនេះ, កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នឹងដើរតួនាទីសំខាន់ សម្រាប់គាំទ្រដល់រាជរដ្ឋាភិបាលក្នុងការអនុវត្តវិធានការគន្លឹះ ឬអនុសាសន៍ដែលចែងជាយថាហេតុនៅក្នុងយុទ្ធសាស្ត្រអន្តរកាលសម្រាប់កម្ពុជាចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ។

បទពិសោធន៍ក្នុងការប្រយុទ្ធនឹងជំងឺកូវីដ-១៩ បានបង្ហាញថា ហិរញ្ញប្បទានសហប្រតិបត្តិការបានផ្តោតសារៈសំខាន់កាន់តែខ្ពស់ឡើងៗដល់កិច្ចគាំពារសង្គម ។ ជាក់ស្តែង កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍មិនត្រឹមតែផ្តល់អាទិភាពដល់ការជំរុញកំណើនសេដ្ឋកិច្ច និងកំណែទម្រង់អភិបាលកិច្ចប៉ុណ្ណោះទេ, ប៉ុន្តែបានគាំទ្រប្រកបដោយប្រសិទ្ធភាព ដល់កិច្ចការសន្តិសុខមនុស្សជាតិ, សុខភាពសាធារណៈ និងសន្តិសុខស្បៀង ដែលជាគោលនយោបាយអាទិភាពក្នុងវិស័យសង្គមកិច្ច និងកិច្ចគាំពារសង្គមរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ការជំរុញសេដ្ឋកិច្ចបៃតង និងការអភិវឌ្ឍសេដ្ឋកិច្ចឆ្លាតវៃ បានក្លាយជាគោលដៅអាទិភាពនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និងក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ស្របពេលដែលកម្ពុជាកំពុងឈានឆ្ពោះទៅសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព, ប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។ ក្នុងន័យនេះ កម្ពុជានឹងត្រៀមលក្ខណសម្បត្តិឱ្យរួចជាស្រេច ដើម្បីទាញយកអត្ថប្រយោជន៍ឱ្យបានជាអតិបរមា និងចូលរួមយ៉ាងសកម្មជាមួយសហគមន៍អន្តរជាតិ ដើម្បីដោះស្រាយបញ្ហាប្រឈមដែលបណ្តាលពីបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ក៏ដូចជាជំរុញបរិវត្តកម្មឌីជីថលនៅកម្ពុជា ។

## III. វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ

ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យវែងឆ្ងាយ និងម៉ឺងម៉ាត់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលគួរឱ្យកត់សម្គាល់ក្នុងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដើម្បីបន្តលើកកម្ពស់ភាពជាដៃគូក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

*១- ភាពជាម្ចាស់ក្នុងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ :* រាជរដ្ឋាភិបាលសម្រេចបានជោគជ័យក្នុងការកៀរគរធនធានពីដៃគូអភិវឌ្ឍន៍, បានតម្រឹមធនធានទាំងនេះជាមួយអាទិភាពដែលមានចែងក្នុងយុទ្ធសាស្ត្រ

ចតុកោណ-ដំណាក់កាលទី ៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងផែនការយុទ្ធសាស្ត្រតាមវិស័យ ក៏ដូចជាតម្រូវការចាំបាច់ និងបន្ទាន់នៃផែនការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិជំងឺកូវីដ-១៩ ។

ក្នុងរយៈពេល ៥ ឆ្នាំ ២០១៩-២០២៣ រាជរដ្ឋាភិបាលកៀរគរបានហិរញ្ញប្បទានសហប្រតិបត្តិការសរុបប្រមាណជាង ១០ ១០០លានដុល្លារអាមេរិក(តទៅហៅកាត់ថាដុល្លារ) គឺប្រមាណជាង ២ ០០០លានដុល្លារជាមធ្យមក្នុង ១ ឆ្នាំ ពោលគឺកើនខ្ពស់ជាងធនធានកៀរគរបានក្នុងឆ្នាំ២០១៤-២០១៨ ដែលមានប្រមាណ ៧ ១០០លានដុល្លារប៉ុណ្ណោះ ។ ក្នុងរយៈពេលដូចគ្នានេះ ឥណទានសម្បទានមាននិន្នាការកើនឡើងជាបន្តបន្ទាប់ និងមានទំហំជាមធ្យមជាង ១ ១០០លានដុល្លារក្នុង ១ ឆ្នាំ ទន្ទឹមនឹងភាពនៅទ្រឹងនៃហិរញ្ញប្បទានឥតសំណង ដែលមានប្រមាណជាមធ្យមក្នុងរង្វង់ ៩០០លានដុល្លារ ក្នុង ១ ឆ្នាំ ។ ការណ៍នេះបានបង្ហាញអំពីការប្តូរទម្រង់ផ្តល់ហិរញ្ញប្បទានជាបណ្តើរៗ ពីហិរញ្ញប្បទានឥតសំណងទៅជាឥណទានសម្បទាន ដែលជាបច្ច័យរបស់កម្ពុជាក្នុងការសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ។ ហិរញ្ញប្បទានសរុបដែលកៀរគរបាន មានទំហំលើស ២៣,៣៧% ធៀបនឹងតម្រូវការធនធានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ដែលបានគ្រោងត្រឹម ៨ ១៥៤លានដុល្លារ ។ អនុបាតនៃហិរញ្ញប្បទានសហប្រតិបត្តិការ ធៀបនឹងផលិតផលក្នុងស្រុកសរុប (ផ.ស.ស) បានកើនពី ៦% ក្នុងឆ្នាំ២០១៧ ដល់ ៧% ក្នុងឆ្នាំ២០១៩ ហើយរក្សាលំនឹងក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ២០១៩-២០២៣ ។ ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ បានស្ថិតក្នុងកម្រិតថេរ ១២៥ដុល្លារ ចាប់ពីឆ្នាំ២០១៩ លើកលែងតែឆ្នាំ២០២០ ដែលបានកើនឡើងដល់ ១៥០ដុល្លារ ដោយសារការបើកផ្តល់ហិរញ្ញប្បទានតែមួយលើក(គំនូរ ៣.១) ។

*គំនូរ ៣.១ : ការកៀរគរហិរញ្ញប្បទាន ឆ្នាំ២០១៩-២០២៣*







*<u>ប្រភព</u> : ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ (ខែកុម្ភៈ ឆ្នាំ២០២៣)*

ទន្ទឹមនឹងជោគជ័យក្នុងការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ, រាជរដ្ឋាភិបាលសម្រេចវឌ្ឍនភាពបានល្អប្រសើរ ក្នុងការតម្រឹមធនធានទាំងនេះជាមួយនឹងអាទិភាពដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ផងដែរ (គំនូរ ៣.២) ។ និយាយជារួម ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការមានទំហំច្រើនជាងតម្រូវការធនធានដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ។

*គំនូរ ៣.២ : ការវិភាជន៍ និងការតម្រើមហិរញ្ញប្បទានតាមវិស័យសំខាន់ៗ ឆ្នាំ២០១៩-២០២៣*




*<u>ប្រភព</u> : - ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ (ខែកុម្ភៈ ឆ្នាំ២០២៣)*
*- ផែនការវិនិយោគសាធារណៈរំកិល៣ឆ្នាំ*

ក្នុងរយៈពេល ៥ ឆ្នាំ ២០១៩-២០២៣, វិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនទទួលបានហិរញ្ញប្បទានច្រើនជាងគេ ប្រមាណជិត ៣ ៥០០លានដុល្លារ ស្មើនឹង ៣៤,៧% នៃហិរញ្ញប្បទានសរុប ពោលគឺមានកំណើនប្រមាណជិត ៦០% ធៀបនឹងរយៈពេល ៥ ឆ្នាំ ២០១៤-២០១៨ ។ បន្ទាប់មកគឺវិស័យសង្គមកិច្ច ដែលទទួលបានហិរញ្ញប្បទាន ប្រមាណ ២ ៧៩០លានដុល្លារ ស្មើនឹង ២៧,៧% នៃហិរញ្ញប្បទានសរុប ក្នុងនោះវិស័យសុខាភិបាលទទួលបាន ៤៥% និងវិស័យអប់រំទទួលបាន ៣៧ % ។ ចំណែកឯវិស័យសេដ្ឋកិច្ចទទួលបាន ២ ២៩៣លានដុល្លារ ស្មើនឹង ២៧,៧% នៃហិរញ្ញប្បទានសរុប កើនឡើងជិត ៨០០លានដុល្លារ ធៀបនឹងឆ្នាំ២០១៤-២០១៨ (គំនូរ ៣.៣) ។

*គំនូរ ៣.៣ : ហិរញ្ញប្បទានតាមវិស័យសំខាន់ៗ ឆ្នាំ២០១៩-២០២៣*




*<u>ប្រភព</u> : ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ (ខែកុម្ភៈ ឆ្នាំ២០២៣)*

២- ***<u>ការពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍</u>*** : ការអនុវត្តយន្តការភាពជាដៃគូនៅគ្រប់ថ្នាក់ (ថ្នាក់ជាតិ និងវិស័យ និងថ្នាក់ក្រោមជាតិ) បានលើកកម្ពស់ភាពជាដៃគូប្រកបដោយបរិយាបន្ន ដោយបង្កើតកាលានុវត្តភាពសម្រាប់តួអង្គអភិវឌ្ឍន៍ (ទាំងដៃគូអភិវឌ្ឍន៍, ទាំងវិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល) បានចូលរួមពិភាក្សាជាមួយរាជរដ្ឋាភិបាល លើគ្រប់ទិដ្ឋភាពនៃកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ទាំងផ្នែកគោលនយោបាយ, ទាំងផ្នែកប្រតិបត្តិការ ។ ប៉ុន្តែ ក្នុងឆ្នាំ២០១៩-២០២៣ ការអនុវត្តយន្តការមួយចំនួនរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ដែលជាទូទៅរៀបចំឡើងទៀងទាត់រៀងរាល់ឆ្នាំ ឬរាល់២ឆ្នាំម្តង ត្រូវបានខកខាន ឬពន្យារពេល ដោយសារកាតព្វកិច្ចនៃការអនុវត្តវិធានការតឹងតៀ្បតក្នុងដំណាក់កាលរាតត្បាតនៃជំងឺកូវីដ-១៩ ។

ទោះស្ថិតក្នុងស្ថានភាពលំបាកយ៉ាងណាក្តី ក៏រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ បានប្តេជ្ញាបន្តកិច្ចសហការ និងពិគ្រោះយោបល់ក្នុងស្មារតីនៃភាពជាដៃគូ, ទន់ភ្លន់ និងបត់បែន តាមរយៈការប្រើប្រាស់ទម្រង់សមស្របតាមសភាពការណ៍ ឬកែសម្រួលទម្រង់នៃដំណើរការក្នុងករណីចាំបាច់ ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាពនៃយន្តការ ។ ជាក់ស្តែង កិច្ចពិគ្រោះយោបល់ទ្វេភាគីដែលរាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តចាប់ពីឆ្នាំ២០១៤មក ត្រូវបានបន្តពង្រឹងបន្ថែមទៀត ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិសេសក្នុងអំឡុងនៃការរាតត្បាតនៃជំងឺកូវីដ-១៩ និងបន្ទាប់ពីបានបើកសកម្មភាពសង្គម-សេដ្ឋកិច្ចឡើងវិញ ។ រីឯវេទិកាពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលជាវេទិកាពិគ្រោះយោបល់ពហុភាគី នៅបន្តដំណើរការជាទៀងទាត់ ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ក្រសួងមានសមត្ថកិច្ចនៃរាជរដ្ឋាភិបាល ។ រាជរដ្ឋាភិបាលក៏បានលើកកម្ពស់ភាពជាដៃគូជាមួយវិស័យឯកជន តាមរយៈវេទិការាជរដ្ឋាភិបាល-ផ្នែកឯកជន ដែលបានផ្តល់ឱកាសឱ្យវិស័យឯកជនបានចូលរួមពិភាក្សាកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ជាមួយរាជរដ្ឋាភិបាល ។

ជាមួយគ្នានេះ ក្រុមការងារបច្ចេកទេសចម្រុះដែលរាជរដ្ឋាភិបាលបានបង្កើត និងដាក់ឱ្យដំណើរការក្នុងឆ្នាំ២០០៤ បានបន្តអនុវត្តសកម្មភាពរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព ទោះបីត្រូវប្រឈមនឹងឥទ្ធិពលនៃការរាតត្បាតនៃជំងឺកូវីដ-១៩ ក៏ដោយ ។ រីឯចំនួនក្រុមការងារបច្ចេកទេសចម្រុះក៏បានកើនឡើងពី ១៧ ក្នុងឆ្នាំ២០០៤ ដល់ ១៩ ក្នុងឆ្នាំ២០១៨ និង ២១ ក្នុងឆ្នាំ២០២៣ ។ ប្រការនេះបានបង្ហាញពីការទទួលស្គាល់នូវសារៈសំខាន់ និងប្រសិទ្ធភាពនៃយន្តការនេះសម្រាប់ពិភាក្សា និងផ្លាស់ប្តូរយោបល់រវាងភាគីពាក់ព័ន្ធ លើកិច្ចការដែលពាក់ព័ន្ធនឹងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក៏ដូចជាការសម្របសម្រួល, ការបែងចែក និងប្រើប្រាស់ធនធានសហប្រតិបត្តិការ ។

*៣- __ការលើកកម្ពស់គណនេយ្យភាព និងតម្លាភាព__ :* នៅដើមឆ្នាំ២០១៩, ក្រុមការងារបច្ចេកទេសចម្រុះបានរៀបចំសូចនាករតាមដានរួមគ្នា (តទៅហៅកាត់ថាសូចនាករ) ដោយបានកំណត់ ៦៦ សកម្មភាព សម្រាប់អនុវត្តក្នុងរយៈពេល ៥ ឆ្នាំ ២០១៩-២០២៣ ។ តាមរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តសូចនាករឆ្នាំ២០២១, ក្រុមការងារបច្ចេកទេសចម្រុះបានអនុវត្ត និងសម្រេចពេញលេញលើសកម្មភាពចំនួន ២២ និងសម្រេចបានមួយផ្នែកលើសកម្មភាពចំនួន ២២ ។ រីឯសកម្មភាពចំនួន ១៣ កំពុងត្រូវបានអនុវត្ត ទន្ទឹមនឹងសកម្មភាពចំនួន ៩ ទៀត មិនអាចអនុវត្តបាន ដោយមានមូលហេតុជាក់លាក់ ។ ក្នុងន័យនេះ វឌ្ឍនភាពក្នុងការអនុវត្តសូចនាករ ឆ្នាំ២០១៩-២០២៣ បានលើកកម្ពស់គណនេយ្យភាពរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។

ទន្ទឹមនឹងនេះ ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីអង្គការមិនមែនរដ្ឋាភិបាលដែលគ្រប់គ្រងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ត្រូវបានកែសម្រួលជាប្រចាំ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់កម្ពុជា ក៏ដូចជាសម្របទៅតាមការវិវត្តនៃភាពជាដៃគូសកលសម្រាប់ស័ក្តិសិទ្ធិភាពនៃកិច្ចអភិវឌ្ឍន៍ ។ លើសពីនេះ ដើម្បីលើកកម្ពស់តម្លាភាពរវាងភាគីពាក់ព័ន្ធ, ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានលើកទឹកចិត្តឱ្យធ្វើបច្ចុប្បន្នភាពតាមកាលបរិច្ឆេទទៀងទាត់ អំពីទិន្នន័យដែលពាក់ព័ន្ធនឹងគម្រោង និងកម្មវិធី ក៏ដូចជាការបើកផ្តល់ហិរញ្ញប្បទានប្រចាំឆ្នាំ និងផែនការប្រើប្រាស់ធនធានសម្រាប់ឆ្នាំបន្តបន្ទាប់តាមគម្រោង និងកម្មវិធីនីមួយៗ ទៅក្នុងប្រព័ន្ធទិន្នន័យទាំងនេះ ដែលព័ត៌មានទាំងអស់នេះត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។

៤- ***ការលើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍*** : បន្ទាប់ពីបានអនុវត្តប្រកបដោយជោគជ័យនូវគោលការណ៍ស្តីពីស័ក្តិសិទ្ធិភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ[1] ក្នុងចន្លោះឆ្នាំ២០០៤-២០១១, រាជរដ្ឋាភិបាលសម្រេចបានលទ្ធផលល្អប្រសើរក្នុងការលើកកម្ពស់ស័ក្តិសិទ្ធិភាពនៃកិច្ចអភិវឌ្ឍន៍[2] ។ ដូចបានរំលេចក្នុងតារាង ៣.១ ដៃគូអភិវឌ្ឍន៍បានប្រើប្រាស់ប្រព័ន្ធជាតិកាន់តែទូលំទូលាយ ។ ជាក់ស្តែង ការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលជាតិបានកើនឡើងពី ៦៤% ក្នុងឆ្នាំ២០១៧ ដល់៨៨% ក្នុងឆ្នាំ២០២១ ទន្ទឹមនឹងពេលដែលការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាតិដោយដៃគូអភិវឌ្ឍន៍ បានកើនពី ៦១% ក្នុងឆ្នាំ២០១៧ ដល់ ៧៤% ក្នុងឆ្នាំ២០២១ ។ រីឯធនធានសហប្រតិបត្តិការ ៨៦% ត្រូវបានកត់ត្រាក្នុងថវិការដ្ឋ ទន្ទឹមនឹងភាពអាចទស្សន៍ទាយបាននៃការបើកផ្តល់ហិរញ្ញប្បទានប្រចាំឆ្នាំ និងសម្រាប់រយៈពេលមធ្យម បានកើនលើស ៩០% ។

*តារាង ៣.១ : ក្របខ័ណ្ឌលទ្ធផលស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍*

| សូចនាករ | ២០១៧ | ២០១៩ | ២០២១ |
|---|---|---|---|
| ១a- ការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលជាតិដោយដៃគូអភិវឌ្ឍន៍ | ៦៤% | ៦៣% | ៨៨% |
| ១b- គុណភាពនៃក្របខ័ណ្ឌលទ្ធផលជាតិរបស់ប្រទេសជាដៃគូ | ៩៣% | - | ៨០%± |
| ២- បរិស្ថានអំណោយផលសម្រាប់សង្គមស៊ីវិល និងស័ក្តិសិទ្ធិភាពកិច្ចអភិវឌ្ឍន៍ | ៥៩% | បានអនុវត្ត | បានអនុវត្ត |
| ៣- គុណភាពនៃកិច្ចពិគ្រោះយោបល់រវាងរដ្ឋ និងឯកជន | ៥៩% | បានអនុវត្ត | បានអនុវត្ត |
| ៤- ការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ | ១០០% | ១០០% | ១០០% |
| ៥a- ភាពអាចទស្សន៍ទាយបានប្រចាំឆ្នាំនៃហិរញ្ញប្បទានសហប្រតិបត្តិការ | ៩៦% | ១២២% | ៩៦% |
| ៥b- ភាពទស្សន៍ទាយបានរយៈពេលមធ្យមនៃហិរញ្ញប្បទានសហប្រតិបត្តិការ | ៩៣% | ៩៩% | ៩៩% |
| ៦- ហិរញ្ញប្បទានសហប្រតិបត្តិការកត់ត្រាក្នុងថវិការដ្ឋ | ៨៣% | ៩២% | ៨៦% |
| ៧- គណនេយ្យភាពទ្វេទិស តាមរយៈការវាយតម្លៃប្រកបដោយបរិយាបន្ន | បានអនុវត្ត | បានអនុវត្ត | - |
| ៨- សមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី | គ្មានទិន្នន័យ | គ្មានទិន្នន័យ | គ្មានទិន្នន័យ |
| ៩a- គុណភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ប្រទេសជាដៃគូ | - | - | ៨០%± |
| ៩b- ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយដៃគូអភិវឌ្ឍន៍ | ៦១% | ៨១% | ៧៤% |
| ១០- ហិរញ្ញប្បទានសហប្រតិបត្តិការឥតភ្ជាប់លក្ខខណ្ឌ | - | - | ៧៧% |

*ប្រភពទិន្នន័យ* : *ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ (ខែកុម្ភៈ ឆ្នាំ២០២៣) និងអង្កេតសម្រាប់ភាពជាដៃគូសកលស្តីពីប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ២០១៩, ២០២១*

កំណត់សម្គាល់ : សូចនាករទី៩a និងទី១០ ត្រូវបានវាស់វែងក្នុងកម្រិតសកល, រីឯសូចនាករទី៨ ពាក់ព័ន្ធនឹងប្រព័ន្ធថវិកាសម្រាប់យេនឌ័រ

[1] ស័ក្តិសិទ្ធិភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការមានន័យថា ការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ រួមទាំងការលើកកម្ពស់ភាពជាម្ចាស់ និងទំនាក់ទំនងរវាងរដ្ឋាភិបាលប្រទេសជាដៃគូ និងដៃគូអភិវឌ្ឍន៍ ដែលផ្តោតទៅលើការតម្រឹម និងសុខដុមនីយកម្មផងដែរ ។

[2] ស័ក្តិសិទ្ធិភាពនៃកិច្ចអភិវឌ្ឍន៍រួមមានសមាសធាតុសំខាន់ចំនួន ៣ គឺ÷ ១)លទ្ធផលក្នុងការអភិវឌ្ឍ, ២)ភាពជាម្ចាស់នៃអាទិភាពក្នុងកិច្ចអភិវឌ្ឍន៍ និង ៣)ភាពជាដៃគូប្រកបដោយបរិយាបន្ន ។ នេះមានន័យថា ស័ក្តិសិទ្ធិភាពនៃកិច្ចអភិវឌ្ឍន៍មានអត្ថន័យទូលំទូលាយជាងស័ក្តិសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងផ្តោតលើបច្ច័យនៃភាពជាដៃគូដែលភាគីពាក់ព័ន្ធបានរួមគ្នាអនុវត្តក្នុងការលើកកម្ពស់សុខុមាលភាព និងការពង្រឹងភាពធន់ក្នុងសេដ្ឋកិច្ច និងសង្គម ។

## IV. ភាពចាំបាច់នៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨

ទន្ទឹមនឹងវឌ្ឍនភាពក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដែលសម្រេចបានក្នុងបណ្តាឆ្នាំកន្លងមក, រាជរដ្ឋាភិបាលនៅបន្តដោះស្រាយបញ្ហាប្រឈមដែលជាបច្ច័យនៃការវិវត្តបរិការណ៍តំបន់ និងសកល និងបរិវត្តកម្មនៃសង្គម-សេដ្ឋកិច្ចកម្ពុជា ។ ជោគជ័យដែលរាជរដ្ឋាភិបាលសម្រេចបានក្នុងការកៀរគរហិរញ្ញប្បទាន ដែលមានទំហំកាន់តែកើនឡើងពីមួយឆ្នាំទៅមួយឆ្នាំ, ពីនីតិកាលមួយទៅនីតិកាលមួយ បានបង្ហាញថា គោលបំណង និងគោលដៅជាយុទ្ធសាស្ត្រ, គោលការណ៍ និងយន្តការ ដែលបានកំណត់ក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ពិតជាមានភាពត្រឹមត្រូវ និងចាំបាច់ ។

ទោះបីកម្ពុជាទទួលរងផលប៉ះពាល់ពីការរាលដាលនៃជំងឺកូវីដ-១៩, ក៏ហិរញ្ញប្បទានសហប្រតិបត្តិការមានភាពធន់នឹងវិបត្តិ ដោយសារដៃគូអភិវឌ្ឍន៍បន្តបើកផ្តល់ហិរញ្ញប្បទានបានច្រើនជាបន្តបន្ទាប់ ទាំងហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន ។ លើសពីនេះ ក្នុងឆ្នាំ២០២០-២០២២ ដៃគូអភិវឌ្ឍន៍ឆ្លើយតបបានល្អប្រសើរ និងទាន់ពេលវេលាស្របតាមការចង្អុលបង្ហាញដ៏ម៉ឺងម៉ាត់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងការប្រយុទ្ធនឹងការរាតត្បាតនៃជំងឺកូវីដ-១៩ និងបានចូលរួមគាំទ្រវិធានការនានាដែលត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីរួមចំណែកស្តារសកម្មភាពសង្គម-សេដ្ឋកិច្ច និងការបើកប្រទេសឡើងវិញ ក្រោយវិបត្តិជំងឺកូវីដ-១៩ ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានកៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ ប្រមាណជាង២០០លានដុល្លារ សម្រាប់ឆ្លើយតបបន្ទាន់ក្នុងវិស័យសុខាភិបាល រួមមានការគ្រប់គ្រងករណីឆ្លង, ការផ្តល់វ៉ាក់សាំង និងបរិក្ខារពេទ្យជាដើម ។ លើសពីនេះ ដៃគូអភិវឌ្ឍន៍បានផ្តល់ធនធានប្រមាណជាង ៨០០លានដុល្លារ សម្រាប់គាំទ្រការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងថ្មី ឆ្នាំ២០២១-២០២៣ ។ ក្នុងរយៈពេលដូចគ្នានេះ ធនធានប្រមាណ ៧៦លានដុល្លារ ត្រូវបានបើកផ្តល់សម្រាប់គាំទ្រវិស័យសង្គម ដែលជាការរួមចំណែកដល់ការស្តារ និងរក្សាលំនឹងជីវភាព និងលើកកម្ពស់សុខុមាលភាពប្រជាជនក្នុងអំឡុងពេលមានវិបត្តិនេះ ។

ភាពធន់នៃហិរញ្ញប្បទានសហប្រតិបត្តិការក្នុងអំឡុងពេលមានវិបត្តិ ពិសេសក្នុងរយៈពេលរាតត្បាតនៃជំងឺកូវីដ-១៩, រចនាសម្ព័ន្ធនៃរំហូរហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍នៅកម្ពុជា ទន្ទឹមនឹងពេលដែលកម្ពុជាត្រូវឆ្លើយតបនឹងបញ្ហាប្រឈមដែលបណ្តាលមកពីការប្រែប្រួលឆាប់រហ័សនៃនិម្មាបនកម្មអភិវឌ្ឍន៍សកល និងបរិវត្តកម្មសង្គម-សេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមក បានបញ្ជាក់ពីកាលានុវត្តភាព និងភាពចាំបាច់ដែលរាជរដ្ឋាភិបាលគប្បីបន្តផ្តល់អាទិភាពខ្ពស់លើការលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្នុងន័យនេះ ហិរញ្ញប្បទានសហប្រតិបត្តិការនៅបន្តតួនាទីសំខាន់ក្នុងការជំរុញ និងពន្លឿនកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ក៏ដូចជាបន្តតួនាទីជាកាតាលីករក្នុងការបំពេញបន្ថែមឱ្យធនធានក្នុងស្រុក និងធនធានពីប្រភពផ្សេងទៀត ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយជាតិ និងគោលនយោបាយតាមវិស័យ ពិសេសការស្តារសង្គម-សេដ្ឋកិច្ចឡើងវិញក្រោយវិបត្តិកូវីដ-១៩ ក៏ដូចជាគាំទ្រកម្ពុជាក្នុងដំណើរចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច និងសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងឈានទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ

២០៥០ ។ ផ្អែកលើសមិទ្ធផលនៃភាពជាដៃគូដូចបានរៀបរាប់ខាងលើ,យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ បានបញ្ជាក់អំពីតម្រូវការ និងភាពចាំបាច់ក្នុងការរៀបចំឱ្យមានយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូឆ្នាំ២០២៤-២០២៨ ដោយត្រូវសម្របទៅនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃបរិការណ៍ក្នុងប្រទេស និងសកល ក៏ដូចជាគោលការណ៍គន្លឹះនៃសេចក្តីថ្លែងការណ៍របស់កិច្ចប្រជុំកំពូលស្តីពីភាពជាដៃគូសកលសម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នាចុងឆ្នាំ២០២២ ។

## V. គោលបំណង និងគោលដៅ

***១- គោលបំណង*** : យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០២៤-២០២៨ មានគោលបំណងបង្កើតនូវក្របខ័ណ្ឌសម្រាប់លើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដើម្បីរួមចំណែកអនុវត្តបណ្តាអាទិភាពជាតិ ដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១, គាំទ្រដំណើរចាកចេញរបស់កម្ពុជា ពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច និងសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។

***២- គោលដៅ*** : ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅជាយុទ្ធសាស្ត្រ ចំនួន ៥ គឺ ÷ (ក) ពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍; (ខ) លើកកម្ពស់ស័ក្តិសិទ្ធិភាពនៃដំណើរការយន្តការភាពជាដៃគូប្រកបដោយបរិយាបន្នរវាងរាជរដ្ឋាភិបាល និងតួអង្គអភិវឌ្ឍន៍; (គ) បង្កើនប្រសិទ្ធភាពនៃការអនុវត្តឧបករណ៍គន្លឹះ ដែលឆ្លុះបញ្ចាំងអំពីការទទួលខុសត្រូវរួមគ្នាលើលទ្ធផលក្នុង

---

**ខ្លឹមសារគន្លឹះនៃសេចក្តីថ្លែងការណ៍**
កិច្ចប្រជុំកំពូលស្តីពីភាពជាដៃគូសកលសម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍
ថ្ងៃទី១២-១៤ ខែធ្នូ ឆ្នាំ២០២២ ទីក្រុងហ្សឺណែវ ប្រទេសស្វីស

*<u>គោលការណ៍នៃភាពជាដៃគូសកល</u>*

១- កិច្ចប្រជុំកំពូលបានវាយតម្លៃវឌ្ឍនភាពក្នុងការអនុវត្តគោលការណ៍ស្តីពីប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ (ភាពជាម្ចាស់, ការផ្តោតលើលទ្ធផល, ភាពជាដៃគូប្រកបដោយបរិយាបន្ន, តម្លាភាព, គណនេយ្យភាព) ដែលនៅមានភាពត្រឹមត្រូវសម្រាប់បន្តណែនាំអនុវត្តសកម្មភាពនានាស្តីពីភាពជាដៃគូ ។

*<u>ក្របខ័ណ្ឌហិរញ្ញប្បទានជាតិរួមបញ្ចូលគ្នា</u>*

២- កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កៀរគរប្រភេទធនធាន និងដៃគូបានកាន់តែច្រើន ។ ការអង្កេតតាមដានភាពជាដៃគូសកលជួយពង្រឹងក្របខ័ណ្ឌហិរញ្ញប្បទានជាតិរួមបញ្ចូលគ្នា ដែលជាឧបករណ៍សំខាន់ក្នុងការជួយតម្រឹមហិរញ្ញប្បទានអភិវឌ្ឍន៍ជាមួយអាទិភាពជាតិ និងសម្របសម្រួលការគាំទ្ររបស់ដៃគូ ។

*<u>សមត្ថភាពជាតិជាកត្តាសំខាន់</u>*

៣- ការពង្រឹងសមត្ថភាពរបស់តួអង្គអភិវឌ្ឍន៍ទាំងអស់ និងស្ថាប័នរដ្ឋនៅតែជាអាទិភាពខ្ពស់របស់ប្រទេសជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍របស់ខ្លួន តាមរយៈការអនុវត្ត“អភិក្រមទូទាំងរដ្ឋាភិបាល” និង“អភិក្រមសង្គមទាំងមូល” ។

*<u>ទិន្នន័យជាកត្តាសំខាន់</u>*

៤- ទិន្នន័យប្រកបដោយគុណភាព, ទាន់ពេលវេលា, សុវត្ថិភាព, តម្លាភាព និងគុណភាពខ្ពស់ក្នុងប្រព័ន្ធស្ថិតិជាតិ គឺជាកត្តាចាំបាច់ ដើម្បីធានាភាពជាដៃគូប្រកបដោយបរិយាបន្ន, ភាពជាម្ចាស់, គណនេយ្យភាព ទ្វេទិស, តម្លាភាព និងការផ្តោតលើលទ្ធផល ។

*<u>ការអង្កេតតាមដានថ្មីស្តីពីភាពជាដៃគូសកល</u>*

៥- ការអង្កេតតាមដានថ្មីស្តីពីភាពជាដៃគូសកល បានបង្កើតលទ្ធភាពសម្រាប់ពិគ្រោះយោបល់ប្រកបដោយបរិយាបន្ន និងជំរុញសកម្មភាពនៅតាមប្រទេស ដែលរួមចំណែកដល់ការលើកកម្ពស់គណនេយ្យភាព ។ វិធានតាមដានថ្មីនេះនឹងវាស់វែងវឌ្ឍនភាពចាប់ពីសេចក្តីប្រកាសទីក្រុងប៉ារីស, ពង្រឹងកិច្ចដំណើរការនៅតាមប្រទេសនីមួយៗ និងលើកកម្ពស់គណនេយ្យភាពរវាងតួអង្គទាំងអស់ ដោយគ្រាន់តែជំនួសការអង្កេតរៀងរាល់ពីរឆ្នាំ ទៅជាការអង្កេតរៀងរាល់បួនឆ្នាំម្តង ដើម្បីផ្តល់កាលានុវត្តភាពដល់ប្រទេសនីមួយៗគិតគូរ និងរៀបចំការពិគ្រោះយោបល់ ក៏ដូចជាអនុវត្តសកម្មភាពនានា ដែលលទ្ធផលត្រូវបានឆ្លុះបញ្ចាំងតាមរយៈការអង្កេតតាមដានថ្មីនេះ ។

កិច្ចអភិវឌ្ឍន៍[3] តាមវិស័យ និងតាមការដ្ឋានកំណែទម្រង់របស់រាជរដ្ឋាភិបាល; (ឃ) ជំរុញការផ្សព្វផ្សាយជាសាធារណៈ ឱ្យបានកាន់តែទូលំទូលាយថែមទៀតនូវព័ត៌មានស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍; និង(ង) អនុវត្ត និងតាមដានលទ្ធផលនៃការអនុវត្តការប្តេជ្ញាស្តីពីការលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

## VI. គោលការណ៍, យន្តការភាពជាដៃគូ និងឧបករណ៍គន្លឹះសម្រាប់អនុវត្តយុទ្ធសាស្ត្រ

***១- គោលការណ៍*** : ផ្អែកលើបទពិសោធន៍របស់កម្ពុជាក្នុងការគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងឧត្តមានុវត្តន៍ដែលត្រូវបានលើកបង្ហាញក្នុងបណ្តាវេទិកាសកលនានាស្តីពីការលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ, យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូឆ្នាំ២០២៤-២០២៨ បានកំណត់គោលការណ៍គន្លឹះដូចខាងក្រោម÷

- ក- រាជរដ្ឋាភិបាលគួសបញ្ជាក់អំពីតម្រូវការក្នុងការពង្រឹង **ភាពជាម្ចាស់** និង**ភាពជាអ្នកដឹកនាំ** សម្រាប់កៀរគរ, គ្រប់គ្រង, សម្របសម្រួល និងតម្រឹមហិរញ្ញប្បទានសហប្រតិបត្តិការ ជាមួយអាទិភាពដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលនយោបាយ ឬផែនការតាមវិស័យ និងកំណែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ក៏ដូចជាបង្កើនប្រភពធនធានផ្ទាល់របស់កម្ពុជាសម្រាប់គាំទ្រដល់កិច្ចអភិវឌ្ឍន៍ ។
- ខ- ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល, ប្រសិទ្ធភាពនៃ **ភាពជាដៃគូប្រកបដោយបរិយាបន្ន**ជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ត្រូវបានបន្តពង្រឹង និងលើកកម្ពស់បន្ថែមទៀត ។
- គ- រាជរដ្ឋាភិបាលទទួលស្គាល់អំពីសារៈសំខាន់ក្នុងការបន្តជំរុញ **គណនេយ្យភាពទ្វេទិស** សម្រាប់អនុវត្តការប្តេជ្ញានានា សំដៅលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។
- ឃ- ក្នុងការលើកកម្ពស់ **តម្លាភាព** នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍, តួអង្គអភិវឌ្ឍន៍ទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យធ្វើបច្ចុប្បន្នភាពនូវទិន្នន័យនានាដែលពាក់ព័ន្ធនឹងគម្រោង ឬកម្មវិធី នៅក្នុងប្រព័ន្ធគ្រប់គ្រងទិន្នន័យជាតិ ហើយរាជរដ្ឋាភិបាលបន្តផ្សព្វផ្សាយព័ត៌មានទាំងនេះ**ជាសាធារណៈ** ឱ្យបានកាន់តែ**ទូលំទូលាយ**បន្ថែមទៀត ។
- ង- កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ត្រូវផ្សារភ្ជាប់ទៅនឹង **លទ្ធផល** តាមរយៈការបញ្ចូលទៅក្នុងក្របខ័ណ្ឌតាមដានដែលបានចែងក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលនយោបាយ និងផែនការតាមវិស័យ ដោយប្រើប្រាស់អភិក្រមសមិទ្ធកម្មភ្ជាប់ជាមួយធនធាន ។

---

[3] លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ផ្តោតលើបច្ច័យ និងចីរភាពនៃការអភិវឌ្ឍ ។ លទ្ធផលក្នុងការអភិវឌ្ឍគឺជាសមាសធាតុមួយនៃស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ហើយផ្តោតលើការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវឧបករណ៍គោលនយោបាយសំខាន់ៗ ដូចជាយន្តការពិភាក្សា, ការរៀបចំកម្មវិធី, ការរៀបចំរបាយការណ៍ ដោយយកចិត្តទុកដាក់ដល់គណនេយ្យភាពទ្វេទិសសម្រាប់សម្រេចលទ្ធផលនៃការអភិវឌ្ឍ ។

***២- យន្តការភាពជាដៃគូ*** ៖ ទន្ទឹមនឹងការអនុវត្តប្រកបដោយជោគជ័យនូវយន្តការភាពជាដៃគូសម្រាប់កៀរគរ, តម្រឹម និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ, រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយ និងសកម្មភាពអាទិភាព សំដៅលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងដាក់ឱ្យដំណើរការនូវយន្តការដូចខាងក្រោម ទាំងនៅកម្រិតជាតិ, កម្រិតវិស័យ និងថ្នាក់ក្រោមជាតិ ដោយប្រកាន់នូវអភិក្រមទន់ភ្លន់ និងបត់បែន ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ។

***ក- <u>កិច្ចពិគ្រោះយោបល់ពហុភាគីថ្នាក់ជាតិ</u>***: រាជរដ្ឋាភិបាលទទួលស្គាល់សារៈសំខាន់នៃភាពជាដៃគូប្រកបដោយបរិយាបន្ន ។ ក្នុងន័យនេះ វេទិកាពិគ្រោះយោបល់ពហុភាគីថ្នាក់ជាតិនឹងផ្តល់កាលានុវត្តភាពសម្រាប់គ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ (ដៃគូអភិវឌ្ឍន៍, វិស័យឯកជន, អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នស្រាវជ្រាវ ។ល។) បានជួបប្រាស្រ័យជាមួយរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងពិភាក្សាអំពីវឌ្ឍនភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ឬវឌ្ឍនភាពនៃការអនុវត្តតាមវិស័យឬ/និងប្រធានបទជាក់លាក់ ក៏ដូចជាកំណត់យុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវអនុវត្តរួមគ្នា ឬដោយតួអង្គនីមួយៗ ។

***ខ- <u>កិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍</u>*** ៖ រាជរដ្ឋាភិបាលបន្តផ្តល់សារៈសំខាន់ដល់កិច្ចពិគ្រោះយោបល់ទ្វេភាគីជាមួយដៃគូអភិវឌ្ឍន៍ ទាំងកម្រិតគោលនយោបាយ និងកម្រិតប្រតិបត្តិការ ។ រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យប្រើប្រាស់យន្តការនេះ ឱ្យបានទូលំទូលាយបន្ថែមទៀត ប្រកបដោយប្រសិទ្ធភាព និងលទ្ធផលខ្ពស់ ។ យន្តការនេះមិនត្រឹមតែសម្រាប់កំណត់អាទិភាព, រៀបចំកម្មវិធី និងធនធានសម្រាប់អនុវត្តអាទិភាពប៉ុណ្ណោះទេ ប៉ុន្តែបានផ្តល់កាលានុវត្តភាពសម្រាប់រួមគ្នាពិនិត្យវឌ្ឍនភាព, កំណត់បញ្ហាប្រឈម និងរួមគ្នាស្វែងរកដំណោះស្រាយ ។ ក្រោមការដឹកនាំ និងសម្របសម្រួលរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (សម្រាប់ហិរញ្ញប្បទានឥតសំណង) និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (សម្រាប់ហិរញ្ញប្បទានសម្បទាន), កិច្ចពិគ្រោះយោបល់ទ្វេភាគីត្រូវរៀបចំឡើងតាមតម្រូវការជាក់ស្តែង និងផ្អែកលើកម្មវិធីនីយកម្មរបស់ដៃគូអភិវឌ្ឍន៍នីមួយៗ ។

***គ-<u>ក្រុមការងារបច្ចេកទេសចម្រុះ</u>*** ៖ ក្រុមការងារបច្ចេកទេសចម្រុះនៅតែជាយន្តការភាពជាដៃគូដ៏មានប្រសិទ្ធភាព សម្រាប់ពិគ្រោះយោបល់ និងសម្របសម្រួលធនធានសហប្រតិបត្តិការនៅកម្រិតវិស័យ ជាមួយដៃគូអភិវឌ្ឍន៍ ។ ជាគោលការណ៍រួម, ក្រុមការងារត្រូវដឹកនាំដោយតំណាងក្រសួង-ស្ថាប័ននៃរាជរដ្ឋាភិបាល និងគាំទ្រដោយអ្នកសម្របសម្រួលខាងដៃគូអភិវឌ្ឍន៍ ។ រហូតមកដល់បច្ចុប្បន្ន ក្រុមការងារភាគច្រើនបានដំណើរការប្រកបដោយប្រសិទ្ធភាពខ្ពស់ និងសម្រេចបានលទ្ធផលល្អប្រសើរ ក្នុងការគាំទ្រដល់ការអនុវត្តគោលនយោបាយ និងផែនការតាមវិស័យ ក៏ដូចជាកម្មវិធីកែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ទន្ទឹមនឹងពេលដែលក្រុមការងារមួយចំនួនបាន និងកំពុងជួបបញ្ហាប្រឈមក្នុងការបំពេញតួនាទី ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបន្តយកចិត្តទុកដាក់តាមដានការអនុវត្តយន្តការនេះ ដើម្បីជំរុញ និងលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចដំណើរការ ទន្ទឹមនឹងការប្រកាន់យកនូវអភិក្រមបត់បែន ហើយក្នុងករណីចាំបាច់ កែសម្រួលរបៀបដំណើរការនៃយន្តការនេះ ។

**ឃ- *វេទិកាពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល*** : រាជរដ្ឋាភិបាលទទួលស្គាល់តួនាទីសំខាន់របស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងការរួមចំណែកអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ។ អង្គការមិនមែនរដ្ឋាភិបាលភាគច្រើនបានកៀរគរធនធាន និងបំពេញការងារក្នុងភាពជាដៃគូជាមួយតួអង្គដទៃទៀត សម្រាប់រួមចំណែកក្នុងការផ្តល់សេវាសាធារណៈក្នុងវិស័យសង្គមកិច្ច ពិសេសនៅតាមសហគមន៍ ។ ក្នុងទិសដៅលើកកម្ពស់ភាពជាដៃគូ, រាជរដ្ឋាភិបាលបន្តដឹកនាំវេទិកាពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល ដើម្បីពិនិត្យវឌ្ឍនភាព និងបញ្ហាប្រឈម ដើម្បីឱ្យពួកគេអាចបង្កើនការចូលរួម និងការគាំទ្របន្ថែមទៀតដល់ការអនុវត្តអាទិភាពនានាក្នុងការអភិវឌ្ឍជាតិ ក៏ដូចជាពង្រឹងទំនាក់ទំនងទ្វេទិស, តម្លាភាព និងប្រសិទ្ធភាពនៃការអនុវត្តសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ។

**ង- *កិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់រាជធានី-ខេត្ត*** : រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យដំណើរការកិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់រាជធានី-ខេត្ត ។ កិច្ចពិគ្រោះយោបល់នេះគឺជាយន្តការសម្របសម្រួល និងពិភាក្សាប្រកបដោយបរិយាបន្ន រវាងរដ្ឋបាលរាជធានី-ខេត្ត, ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល និងតួអង្គពាក់ព័ន្ធនានា ដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈនៅថ្នាក់ក្រោមជាតិ និងអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឈានទៅសម្រេចបានគោលដៅអភិវឌ្ឍន៍ថ្នាក់រាជធានី-ខេត្ត តាមរយៈការកំណត់អាទិភាព និងការផ្តល់ការគាំទ្រសមស្រប ។ លើសពីនេះ កិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់រាជធានី-ខេត្ត ក៏ជាយន្តការកម្រិតបច្ចេកទេស ដើម្បីគាំទ្រការអនុវត្តគោលនយោបាយ និងផែនការអភិវឌ្ឍន៍រាជធានី-ខេត្ត និងពិនិត្យវឌ្ឍនភាព, បញ្ហាប្រឈម និងកំណត់វិធានការសម្រាប់សម្របសម្រួលការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការ ។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានឹងផ្តល់ការគាំទ្របច្ចេកទេសដល់រដ្ឋបាលរាជធានី-ខេត្ត តាមការចាំបាច់ ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការ ដូចជាការកំណត់ប្រធានបទ, របៀបវារៈ និងការកំណត់សមាសភាពចូលរួម ។ ដៃគូអភិវឌ្ឍន៍, អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជនទាំងអស់ដែលកំពុងប្រតិបត្តិការនៅថ្នាក់ក្រោមជាតិ ត្រូវបានលើកទឹកចិត្តឱ្យចូលរួមក្នុងយន្តការពិគ្រោះយោបល់នេះ ។

**ច- *កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការតំបន់*** : ស្របពេលដែលកម្ពុជាកំពុងរៀបចំចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច, កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការតំបន់បានផ្តល់កាលានុវត្តភាពសម្រាប់កម្ពុជាចូលរួម និងចែករំលែកបទពិសោធន៍ក្នុងកិច្ចអភិវឌ្ឍន៍ ជាមួយប្រទេសកំពុងអភិវឌ្ឍន៍ដទៃទៀត ។ តាមរយៈយន្តការនៃកិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការតំបន់, កម្ពុជាអាចចែករំលែក និងទទួលបានចំណេះដឹង និងបទពិសោធន៍ពាក់ព័ន្ធនឹងភាពជោគជ័យ, ឧត្តមានុវត្តន៍ និងគំរូកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ។ ដោយមានការគាំទ្រ និងសម្របសម្រួលពីដៃគូអភិវឌ្ឍន៍, កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការតំបន់ អាចដំណើរការតាមរយៈវគ្គបណ្តុះបណ្តាល, សិក្ខាសាលាចែករំលែកបទពិសោធន៍ និងទស្សនកិច្ចសិក្សា ឬការបញ្ជូនអ្នកស្ម័គ្រចិត្ត និងអ្នកជំនាញ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការតំបន់ និងសកល ដូចជាក្នុងក្របខ័ណ្ឌនៃអង្គការសហប្រជាជាតិជាដើម ។

*ធ- ភាពជាដៃគូសកលសម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍* : គោលការណ៍ និងអាទិភាពក្នុងក្របខ័ណ្ឌនៃយន្តការភាពជាដៃគូសកលសម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការ នៅតែមានសារៈសំខាន់សម្រាប់គាំទ្រដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការជំរុញ និងលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងបន្តសហការជាមួយដៃគូអភិវឌ្ឍន៍ និងស្ថាប័នពាក់ព័ន្ធ ដើម្បីចូលរួមក្នុងដំណើរការនៃការធ្វើអង្កេតតាមដានជាសកលស្តីពីភាពជាដៃគូ ។ អភិក្រម និងវិធីសាស្ត្រក្នុងការធ្វើអង្កេតតាមដានជាសកលនៃភាពជាដៃគូ ដោយអនុលោមតាមលទ្ធផលនៃកិច្ចប្រជុំកំពូលស្តីពីភាពជាដៃគូ ឆ្នាំ២០២២ នឹងត្រូវប្រើប្រាស់សម្រាប់ជាមូលដ្ឋានក្នុងការពង្រឹងការអនុវត្តសកម្មភាពអាទិភាព ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ។

***៣- ឧបករណ៍គន្លឹះ*** : រាជរដ្ឋាភិបាលបានកំណត់ឧបករណ៍គន្លឹះសម្រាប់អនុវត្តសកម្មភាពអាទិភាព និងតាមដានលទ្ធផលនៃការអនុវត្តដូចខាងក្រោម ÷

*ក- ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីអង្គការមិនមែនរដ្ឋាភិបាល* : ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីអង្គការមិនមែនរដ្ឋាភិបាល ដែលគ្រប់គ្រងដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គឺជាប្រព័ន្ធជាតិសម្រាប់គ្រប់គ្រងព័ត៌មាន និងទិន្នន័យគម្រោង និងកម្មវិធីដែលដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលផ្តល់ធនធានសម្រាប់អនុវត្ត ។ ប្រព័ន្ធទិន្នន័យទាំងពីរនេះមានតម្លាភាព ម្យ៉ាង ដោយសារដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំនូវព័ត៌មានដែលពាក់ព័ន្ធនឹងគម្រោង និងកម្មវិធីរបស់ខ្លួន, និងម្យ៉ាងទៀត ដោយសារព័ត៌មានក្នុងប្រព័ន្ធទិន្នន័យទាំងនេះត្រូវបានដាក់ឱ្យប្រើប្រាស់ទូលំទូលាយ និងបានផ្សព្វផ្សាយជាសាធារណៈ តាមរយៈតំណភ្ជាប់ WWW.ODACAMBODIA.COM ។ លើសពីនេះ រចនាសម្ព័ន្ធ និងទម្រង់នៃប្រព័ន្ធទិន្នន័យត្រូវបានធ្វើបច្ចុប្បន្នភាពជាប្រចាំ និងកែសម្រួលតាមការចាំបាច់ ដើម្បីឆ្លើយតបនឹងតម្រូវការ និងការវិវត្តនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

*ខ- របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា* : ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជានឹងបន្តរៀបចំរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា ដែលជាឧបករណ៍សំខាន់សម្រាប់ធ្វើការវិភាគ, ពិនិត្យ និងតាមដានវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ ។ របាយការណ៍នេះត្រូវបានរៀបចំយ៉ាងទៀងទាត់ ដោយផ្តោតសំខាន់លើការវិភាគអំពីការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ និងធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល, វាយតម្លៃការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ក្នុងវិស័យអាទិភាពមួយចំនួន ដូចជាបម្រែបម្រួលអាកាសធាតុ, ការគាំទ្រផ្នែកឯកជន និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា, វាយតម្លៃប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ តាមរយៈការប្រើប្រាស់សូចនាករសកល, វឌ្ឍនភាពក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ក៏ដូចជាវឌ្ឍនភាពរបស់កម្ពុជាក្នុងការត្រៀមចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួចជាដើម ។

***ឥ- សូចនាករតាមដានរួមគ្នា*** **:** សូចនាករតាមដានរួមគ្នាដែលត្រូវបានរៀបចំដោយក្រុមការងារបច្ចេកទេសចម្រុះ គឺជាឧបករណ៍សម្រាប់លើកកម្ពស់គណនេយ្យភាពទ្វេទិសរវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍ ។ ទន្ទឹមនឹងនេះ សូចនាករតាមដានរួមគ្នាបានក្លាយជាក្របខ័ណ្ឌសម្រាប់កំណត់ទិសដៅការងាររយៈពេលមធ្យមតាមវិស័យនីមួយៗ និងការដ្ឋានកែទម្រង់ស្នូលរបស់រាជរដ្ឋាភិបាល ។ ទន្ទឹមនឹងវឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការរៀបចំសូចនាករតាមដានរួមគ្នានឹងត្រូវពង្រឹងបន្ថែមទៀតជាមួយដំណើរការនៃការរៀបចំថវិការដ្ឋ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការផ្សារភ្ជាប់គោលនយោបាយទៅនឹងថវិកា និងសមិទ្ធកម្ម ។ សូចនាករតាមដានរួមគ្នាត្រូវបានរៀបចំដោយផ្អែកលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យ ។

## VII. ក្របខ័ណ្ឌលទ្ធផល

គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ស.អ.ក/ក.អ.ក) នឹងដឹកនាំកិច្ចសម្របសម្រួលការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ និងធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពជូនរាជរដ្ឋាភិបាល ។ ក្របខ័ណ្ឌលទ្ធផលដូចដែលបានកំណត់ដូចខាងក្រោម នឹងត្រូវធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌលទ្ធផលនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០២៤-២០២៨ ក៏ដូចជាក្របខ័ណ្ឌលទ្ធផលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា÷

| គោលដៅ | សូចនាករ | ប្រភព | ស្ថាប័ន |
|---|---|---|---|
| ***គោលដៅទី ១:*** *ពង្រឹងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍* | ១- ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ (ដុល្លារ និងអនុបាតធៀបនឹង ផ.ស.ស)<br>២- ការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលជាតិដោយដៃគូអភិវឌ្ឍន៍ (យ៉ាងតិច៨៥%)<br>៣- ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយដៃគូអភិវឌ្ឍន៍ (យ៉ាងតិច៧៥%) | -ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ<br>-របាយការណ៍ស្តីពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច<br>-របាយការណ៍ស្តីពីការធ្វើអង្កេតទីក្រុងប៊ូសាន | -គ.ស.អ.ក/ក.អ.ក<br>-ក្រសួងផែនការ<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| ***គោលដៅ ទី២:*** *ជំរុញប្រសិទ្ធភាពដំណើរការនៃយន្តការភាពជាដៃគូប្រកបដោយបរិយាបន្ន រវាងរាជរដ្ឋាភិបាល និងតួអង្គអភិវឌ្ឍន៍* | ១- ការរៀបចំកិច្ចពិគ្រោះយោបល់ទ្វេភាគី, កិច្ចពិគ្រោះយោបល់ភាពជាដៃគូ, វេទិកាភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងតួអង្គអភិវឌ្ឍន៍<br>២- ការពិនិត្យ និងវាយតម្លៃដំណើរការរបស់ក្រុមការងារបច្ចេកទេសចម្រុះ (រៀងរាល់ឆ្នាំ) | -ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ<br>-របាយការណ៍និងវាយតម្លៃលទ្ធផលនៃក្រុមការងារបច្ចេកទេសចម្រុះ<br>-របាយការណ៍ស្តីពីវឌ្ឍនភាពក្នុងការអនុវត្តយន្តការភាពជាដៃគូ | -គ.ស.អ.ក/ក.អ.ក<br>-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>-ក្រសួងមហាផ្ទៃ |

| | | | |
|---|---|---|---|
| ***គោលដៅទី៣ :*** *បង្កើនប្រសិទ្ធភាពនៃការអនុវត្តឧបករណ៍គោលនយោបាយដែលឆ្លុះបញ្ចាំងការទទួលខុសត្រូវរួមគ្នាលើលទ្ធផលក្នុងការអភិវឌ្ឍតាមវិស័យ និងការដ្ឋានកំណែទម្រង់របស់រាជរដ្ឋាភិបាល* | ១- ការរៀបចំ និងអនុម័តសូចនាករតាមដានរួមគ្នា<br>២- តាមដានវឌ្ឍនភាពក្នុងការអនុវត្តសូចនាករតាមដានរួមគ្នា (រៀងរាល់ឆ្នាំ) | -របាយការណ៍វឌ្ឍនភាពក្នុងការអនុវត្តសូចនាករតាមដានរួមគ្នា<br>-របាយការណ៍ស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ | -គ.ស.អ.ក/ក.អ.ក<br>-ក្រុមការងារបច្ចេកទេសចម្រុះ |
| ***គោលដៅទី៤ :*** *ជំរុញការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មានស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ឱ្យបានទូលំទូលាយ* | ១-ធ្វើបច្ចុប្បន្នភាពជាទៀងទាត់នូវទិន្នន័យក្នុងប្រព័ន្ធទិន្នន័យកម្ពុជាស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការ (រៀងរាល់ឆ្នាំ)<br>២-ហិរញ្ញប្បទានសហប្រតិបត្តិការកត់ត្រាក្នុងថវិការដ្ឋ (យ៉ាងតិច៩០%) | -ថវិការដ្ឋ និងប្រព័ន្ធទិន្នន័យកម្ពុជាស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការ<br>-របាយការណ៍ស្ដីពីការធ្វើអង្កេតទីក្រុងប៊ូសាន<br>-របាយការណ៍ស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ | -ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>-គ.ស.អ.ក/ក.អ.ក |
| ***គោលដៅទី៥:*** *អនុវត្ត និងតាមដានលទ្ធផលនៃការអនុវត្តការប្ដេជ្ញាស្ដីពីការលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍* | ១-ការវាយតម្លៃវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ (រៀងរាល់ឆ្នាំ)<br>២- ការវាយតម្លៃអំពីស័ក្តិសិទ្ធិភាពនិងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ (រៀងរាល់ឆ្នាំ) | -របាយការណ៍ស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា<br>-របាយការណ៍ស្ដីពីលទ្ធផលនៃការធ្វើអង្កេតទីក្រុងប៊ូសាន | -គ.ស.អ.ក/ក.អ.ក |

## VIII. សេចក្តីសន្និដ្ឋាន

ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលបានទទួលស្គាល់ថាហិរញ្ញប្បទានសហប្រតិបត្តិការបានបំពេញតួនាទីជាកាតាលីករសំខាន់ ដើម្បីបំពេញបន្ថែមឱ្យធនធានក្នុងប្រទេស និងធនធានដទៃទៀត សម្រាប់កិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ។ ការកៀរគរ, ការគ្រប់គ្រង និងការប្រើប្រាស់ធនធានទាំងនេះប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព បានចូលរួមចំណែកក្នុងការសម្រេចបានសមិទ្ធផលគន្លឹះៗជាច្រើន ដូចជាការកាត់បន្ថយភាពក្រីក្រ, វឌ្ឍនភាពក្នុងការអនុវត្តសូចនាករសំខាន់ៗនៃផ្នែកសង្គម-សេដ្ឋកិច្ច សម្រាប់ការរីកចម្រើន និងវិបុលភាពសង្គម ។ សមិទ្ធផលទាំងនេះគឺជាសក្ខីកម្មដែលបង្ហាញអំពីការដឹកនាំដ៏ប៉ិនប្រសប់ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ។ លើសពីនេះ ក៏បញ្ជាក់ពីភាពត្រឹមត្រូវនៃយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដែលបានកំណត់គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពអាទិភាព សម្រាប់គ្រប់គ្រង និងសម្របសម្រួលហិរញ្ញប្បទានសហប្រតិបត្តិការ ក៏ដូចជាបន្តពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដើម្បីសម្រេចអាទិភាពក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ។

រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានបញ្ជាក់សារជាថ្មីអំពីសារៈសំខាន់នៃហិរញ្ញប្បទានសហប្រតិបត្តិការ និងភាពចាំបាច់ក្នុងការលើកកម្ពស់ស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាពនៃការគ្រប់គ្រង និងប្រើប្រាស់ធនធានទាំងនេះ ។ ក្នុងស្មារតីនេះ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ ត្រូវបានរៀបចំឡើង ក្នុងគោលដៅរួមចំណែកអនុវត្តឱ្យបានសម្រេចនូវគោលដៅជាយុទ្ធសាស្ត្រទាំង ៥ ដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ដើម្បីឈានទៅសម្រេចគោលដៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០, គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, ការចាកចេញជាស្ថាពរពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។ ទន្ទឹមនឹងនេះ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការទាំងនេះ, យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ បានកំណត់គោលដៅ, គោលការណ៍, យន្តការ និងឧបករណ៍សម្រាប់អនុវត្ត ព្រមទាំងបានរៀបចំក្របខ័ណ្ឌលទ្ធផលសម្រាប់តាមដាន និងវាយតម្លៃ ។

ក្នុងស្មារតីនៃភាពជាដៃគូប្រកបដោយបរិយាបន្នសម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ, រាជរដ្ឋាភិបាលបន្តលើកកម្ពស់កិច្ចសហការឱ្យកាន់តែជិតស្និទ្ធថែមទៀត ជាមួយដៃគូអភិវឌ្ឍន៍ និងតួអង្គអភិវឌ្ឍន៍ដទៃទៀត ដើម្បីប្រែក្លាយបណ្តាអាទិភាពដែលបានចែងក្នុងយុទ្ធសាស្ត្រនេះឱ្យទៅជាសកម្មភាពជាក់ស្តែង សម្រាប់គាំទ្រដល់ការសម្រេចបាននូវគោលដៅអាទិភាពដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ ។ ក្នុងន័យនេះ កម្ពុជាសង្ឃឹមថា ភាពជាដៃគូស្មើភាព, គណនេយ្យភាពទ្វេទិស និងសុខដុមនីយកម្ម ត្រូវបានពង្រឹងថែមទៀត ក្រោមភាពជាម្ចាស់របស់រាជរដ្ឋាភិបាល តាមរយៈការតម្រង់ទិស និងកិច្ចសម្របសម្រួល ដើម្បីបន្តលើកកម្ពស់គុណភាព និងស័ក្តិសិទ្ធិភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

---